សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥៥៦ / ០៨-០៦-២០១២
សាលដីកា
លេខ ០១ ក្រVI "ញ/១១-០១-២០១៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តាងនាមប្រជារាស្ត្រខ្មែរ

## សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍

ឆ្នាំពីរពាន់ដប់បី ខែមករា ថ្ងៃទីដប់មួយ វេលាម៉ោងប្រាំបីព្រឹក បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ ដែលមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

១-លោក [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រមប្រឹក្សា

៣-លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៥៥៦ ចុះថ្ងៃទី ០៨-០៦-២០១២ រវាង:

**ជនជាប់ចោទឈ្មោះ** [redacted]ស ភេទ ប្រុស អាយុ ៣៦ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើស្រែ កើតនៅភូមិអង្រ្កងទី២ ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង[redacted] ឃុំក្រពៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ[redacted]) ប្រពន្ធឈ្មោះ [redacted] មានកូន ៣នាក់ ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារចំនួន ៨ឆ្នាំ ពីបទៈ រំលោភសេពសន្ថវៈ ។ ឃុំខ្លួនថ្ងៃទី ២៧-០៧-២០១១ ។

**ត្រូវចោទពីបទៈ** រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិព្រៃគ្រេស ឃុំក្រពៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី ២៥-០៧-២០១១ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

មានមេធាវីការពារ ឈ្មោះ[redacted]ចន្ថា ។

**និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ**[redacted]លេខ ភេទ ស្រី អាយុ ៤៤ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើស្រែ មានទីលំនៅភូមិព្រៃ[redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ[redacted](ស) ប្តីឈ្មោះ [redacted]ានកូន ២នាក់ ។

៦១៤



Scanned with CamScanner

ជនរងគ្រោះឈ្មោះ [redacted] និត ភេទ ស្រី អាយុ ២៦ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ធ្វើស្រែ មានទីលំនៅភូមិព្រៃគ្រេស ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ។

ព្រះរាជអាជ្ញារងឈ្មោះ [redacted] ណូរ៉ា ជាអ្នកប្តឹងឧទ្ធរណ៍ ។

<u>ឯរឿងហេតុដូចខាងក្រោម:</u>

កាលពីថ្ងៃទី ២៥-០៧-២០១១ វេលាម៉ោង ១ និង ៣០ នាទីរសៀល នៅចំណុច ចម្ការដំឡូងផ្លូកអំពក ស្ថិតនៅក្នុងភូមិព្រៃគ្រេស ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ឈ្មោ [redacted] ស បានធ្វើសកម្មភាពចាប់រំលោភទៅលើឈ្មោះ [redacted] និត ដោយផ្តួលទៅនឹង ដី រួចច្រ [redacted] និងយកប្រ [redacted] អាន និត ហេតុបានសម្រេច ។ ក្រោយមក សមត្ថកិច្ចបានធ្វើការស្រាវជ្រាវចាប់ឃាត់ ខ្លួនជនល្មើស រួចបញ្ជូនទៅតុលាការដើម្បីចាត់ការតាមច្បាប់ ។ តាមប្រវត្តិរបស់ឈ្មោះ [redacted] ស កន្លងមក នៅក្នុងឆ្នាំ២០០០ ជននេះធ្លាប់បានជាប់ពន្ធនាគារចំនួន ៨ឆ្នាំម្តងរួចមក ហើយ ពីបទៈ រំលោភសេពសន្ថវៈនេះដែរ ហើយទើបដោះលែងឲ្យមានសេរីភាពវិញក្នុង ឆ្នាំ ២០០៨ នេះ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១០"ច" ចុះថ្ងៃទី ១៣-០៣-២០១២ របស់ សាលាដំបូងខេត្តព្រៃវែង សម្រេចមានខ្លឹមសារដូចខាងក្រោម:

១-ប្តូរបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ស ពីមាត្រា ២៣៩ (បទៈ រំលោភសេពសន្ថវៈ) មកមាត្រា ២៤១ (ពីបទៈ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស ទាក់ទងនឹងជនរងគ្រោះ) នៃក្រមព្រហ្មទណ្ឌវិញ ។

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ស ភេទ ប្រុស អាយុ ៣៦ឆ្នាំ (មានសារពើ ជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៩ឆ្នាំ ក្នុងនេះអនុវត្តទោសពន្ធនាគារ ៨ឆ្នាំ គិតពីថ្ងៃឃុំខ្លួន (២៧-០៧-២០១១) ទោសសល់ពីនេះត្រូវព្យួរ ពីបទៈ រំលោភសេព សន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅភូមិព្រៃគ្រេស ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី ២៥-០៧-២០១១ បទល្មើសមានចែងឲ្យផ្តន្ទា ទោសតាមមាត្រា ២៤១, ៩៤ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ០៨-០២-២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៣-០៣-២០១២ ចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ និងដើមបណ្តឹង រដ្ឋប្បវេណី សម្រេចបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣-០៣-២០១២ របស់លោក [redacted] ណូរ៉ា ។

- បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី ០៥-១១-២០១២ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍។

១១៥



Scanned with CamScanner

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ[redacted]ស (ចូល)
- មេធាវីការពារជនជាប់ចោទ ឈ្មោះ[redacted] ចន្ថា (ចូល)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]លេខ (មិនចូល)
- ជនរងគ្រោះឈ្មោះ[redacted]រិត (មិនចូល)

## ប្រធានក្រុមប្រឹក្សាសួរចម្លើយអង្គហេតុ

- ជនជាប់ចោទឈ្មោះ[redacted]ស បានឆ្លើយថាៈ ខ្លួនទទួលយកមេធាវី[redacted]ចន្ថា ការពារឲ្យខ្លួនតាមច្បាប់ ។ ពីមុន ខ្លួនធ្លាប់បានជាប់ទោសម្តងពីបទៈ រំលោភ ហើយពេលនេះ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ ខ្លួនសំណូមពរសុំរួចខ្លួនពីបទចោទ ។

## តំណាងមហាអយ្យការសន្និដ្ឋាន

តាមបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា សុំឲ្យក្រុមប្រឹក្សាសម្រេចតាមច្បាប់។

## មេធាវី នូ ចន្ថា សន្និដ្ឋាន់

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា សុំតម្កល់សាលក្រមរបស់តុលាការថ្នាក់ក្រោម ។

## ក្រុមប្រឹក្សាជំនុំជម្រះថយពិភាក្សា និងប្រកាសសាលដីកា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣-០៣-២០១២ របស់លោក [redacted] ណ្ឌពីធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-បណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការលើចំណុចទី២ នៃសាលក្រមព្រហ្មទណ្ឌលេខ ១០ "ច" ចុះថ្ងៃទី ១៣-០៣-២០១២ ដោយផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]ស ដាក់ពន្ធនាគារទាបពេក និងសម្រេចព្យួរទោស ប៉ុន្តែពុំមានបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ដូចនេះឃើញថា អង្គហេតុនៃពិរុទ្ធភាពលើជនជាប់ចោទត្រូវបានចូលស្ពាន ដូចនេះ ក្រុមប្រឹក្សាពិចារណាតែទៅលើការដាក់ទណ្ឌកម្មលើជនជាប់ចោទប៉ុណ្ណោះ ។

៣-ជនជាប់ចោទបានឆ្លើយនៅសាលាឧទ្ធរណ៍ថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ដោយខ្លួនមានសាក្សីគ្រប់គ្រាន់ ប៉ុន្តែចម្លើយនេះ ក្រុមប្រឹក្សាមិនលើកយកមកពិចារណាឡើយ ។

៤-កាលដែលសាលាដំបូងខេត្តព្រៃវែង សម្រេចផ្តន្ទាទោសជនជាប់ចោទកំណត់ ៩ឆ្នាំ ប៉ុន្តែអនុវត្តក្នុងពន្ធនាគារកំណត់ ៤ឆ្នាំ និងព្យួរទោសដែលនៅសល់ ឃើញថា ពុំត្រឹមត្រូវតាមមាត្រា ១០៧ នៃក្រមទណ្ឌដែលខ្លួនលើកយកមកសំអាងហេតុនោះទេ ហើយការលើកយកមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌយកមកសម្រេច ក៏ពុំត្រឹមត្រូវដែរ ដោយហេតុថា អង្គហេតុនេះមិនអាចលើកយកមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌមកសំអាងបានឡើយ ។

៥-គប្បីក្រុមប្រឹក្សាពិចារណាលើចំណុចផ្តន្ទាទោសជនជាប់ចោទឡើងវិញ ។ /.-

១១៦



Scanned with CamScanner

៦-ចំណុចទី២ នៃសាលក្រមព្រហ្មទណ្ឌលេខ: ១០"ច" ចុះថ្ងៃទី១៣-០៣-២០១២ របស់សាលាដំបូងខេត្តព្រៃវែង សម្រេចពុំត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ទេ គប្បីបដិសេធចោល និង សម្រេច ផ្តន្ទាទោសលើជនជាប់ចោទដូចការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣-០៣-២០១២ របស់លោក [redacted]ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-លុបចំណុចទី២ នៃសាលក្រមព្រហ្មទណ្ឌលេខ:១០"ច"ចុះថ្ងៃទី១៣-០៣-២០១២របស់សាលាដំបូងខេត្តព្រៃវែង និង សម្រេចជាថ្មី ដូចខាងក្រោម:

ផ្តន្ទាទោសលើឈ្មោះ[redacted]ស ដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ ពីបទ: រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅភូមិព្រៃគ្រេស ឃុំក្រពៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីថ្ងៃទី២៥-០៧-២០១១ បទល្មើសមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

៣-បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ[redacted] ស ។

៤-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី១១-០១-២០១៣ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹង ទុកសិទ្ធិឲ្យប្តឹងតវ៉ាតាមកំណត់ច្បាប់ ។ ស.

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខ[redacted] | ហត្ថលេខ[redacted], [redacted] | ហត្ថលេខា[redacted] |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម-
ភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]





Scanned with CamScanner